អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ភ្នំពេញ ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៩

# សហចៅក្រមស៊ើបអង្កេត
# ចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នាក្នុងសំណុំរឿង យឹម ទិត្យ

សំណុំរឿងលេខ ០០៤/៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

នៅថ្ងៃនេះ សហចៅក្រមស៊ើបអង្កេត បានចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នានៅក្នុងសំណុំរឿង យឹម ទិត្យ ផ្អែកតាមការខ្វែងយោបល់គ្នាថាតើ យឹម ទិត្យ ត្រូវស្ថិត ឬក៏មិនត្រូវស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ ឬជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ។

សហចៅក្រមស៊ើបអង្កេតជាតិ យល់ឃើញថា យឹម ទិត្យ មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ក្នុងនាមមេដឹកនាំជាន់ខ្ពស់ ឬជាជនម្នាក់ដែលទទួលខុសត្រូវខ្ពស់បំផុតនោះទេ ហើយលើកលែងការចោទប្រកាន់លើ យឹម ទិត្យ ដោយសារមូលហេតុនេះ។ ដើម្បីឈានដល់សេចក្ដីសម្រេចបែបនេះ សហចៅក្រមស៊ើបអង្កេតជាតិ បានពិចារណាលើកម្រិតនៃការចូលរួមរបស់ យឹម ទិត្យ និងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ព្រមទាំងកត្តាផ្សេងៗទៀត ដូចជា ខ្លឹមសារនៃច្បាប់ និងកិច្ចព្រមព្រៀង អ.វ.ត.ក. ព្រមទាំងគោលបំណងនៃអ្នកតាក់តែងកិច្ចព្រមព្រៀង និង ច្បាប់ទាំងនោះ។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិ យល់ឃើញថា យឹម ទិត្យ ស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ក្នុងនាមជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ហើយមានភស្តុតាងគ្រប់គ្រាន់ដើម្បីចោទបញ្ជូនគាត់ទៅជំនុំជម្រះចំពោះបទចោទ អំពើប្រល័យពូជសាសន៍លើកម្ពុជាក្រោម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម ព្រមទាំងបទឧក្រិដ្ឋកម្មក្រោមច្បាប់កម្ពុជា។ បទចោទខ្លះមិនមានភស្តុតាងបញ្ជាក់ទេនៅក្នុងអំឡុងពេលស៊ើបសួរ ហេតុនេះ ត្រូវលើកលែងបទចោទទាំងនោះ។

សហចៅក្រមស៊ើបអង្កេតទាំងពីរ បានដាក់ដីកាដំណោះស្រាយរបស់ខ្លួនជាភាសាផ្លូវការរៀងៗខ្លួន ដោយសំណៅបកប្រែនឹងដាក់តាមក្រោយឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។ ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតទាំងពីរ ផ្ដល់ជូនសេចក្ដីសង្ខេបនៃសំអាងហេតុរៀងខ្លួនទាំងជាភាសាខ្មែរ និងជាភាសាអង់គ្លេស ដើម្បីធានាថា សាធារណជនទទួល

បានព័ត៌មានគ្រប់គ្រាន់អំពីលទ្ធផលនៃសំណុំរឿង រហូតដល់ពេលសំណៅបកប្រែទាំងស្រុងត្រូវបានដាក់។ សេចក្ដីសង្ខេបទាំងនេះ មានភ្ជាប់ជាមួយនឹងសេចក្ដីប្រកាសព័ត៌មាននេះ ហើយសហចៅក្រមស៊ើបអង្កេតទាំងពីរ សូមយោងលើសេចក្ដីសង្ខេបទាំងនេះសម្រាប់សេចក្ដីលម្អិតថែមទៀត។

សហចៅក្រមស៊ើបអង្កេតទាំងពីរក៏បានចេញដីកាសម្រេចដាច់ដោយឡែកពីគ្នាលើភាពអាចទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។

ខ្លឹមសារទាំងស្រុងនៃដីកាដំណោះស្រាយទាំងពីរជាសំណៅសាធារណៈដោយមានការកោសលុប
អាចរកបានតាមរយៈ៖

https://www.eccc.gov.kh/sites/default/files/documents/courtdoc/%5Bdate-in-tz%5D/D381_KH_Redacted.PDF
https://www.eccc.gov.kh/sites/default/files/documents/courtdoc/%5Bdate-in-tz%5D/D382_EN_redacted.PDF

សហចៅក្រមស៊ើបអង្កេតទាំងពីរ ចុះហត្ថលេខារួមគ្នា លើដីកាសម្រេចបញ្ចប់កិច្ចស៊ើបសួរ ដែលនៅសេសសល់ទាំងអស់ក្នុងចំណោមកិច្ចស៊ើបសួរសំណុំរឿង ០០៤។ នេះបានបិទបញ្ចប់ កិច្ចការងារស៊ើបសួរទាំងអស់ ដែលសហចៅក្រមស៊ើបអង្កេត ត្រូវបានប្រគល់ជូន។

# សេចក្តីសង្ខេបរបស់សហចៅក្រមស៊ើបអង្កេតជាតិ

សហចៅក្រមស៊ើបអង្កេតជាតិ តាំងពីក្នុងសំណុំរឿង ០០១ ទទួលស្គាល់ថា បទឧក្រិដ្ឋកម្ម ត្រូវបានប្រព្រឹត្ត ក្នុងក្របខ័ណ្ឌនៃការអនុវត្តគោលនយោបាយ ដោយរបបកម្ពុជាប្រជាធិបតេយ្យ ទូទាំងប្រទេស ហើយមានផលវិបាកធ្ងន់ធ្ងរ និងមានវិសាលភាពធំធេង។ មានជនសង្ស័យជាច្រើន អាចជាប់ពាក់ព័ន្ធ។ អាស្រ័យហេតុនេះ អ.វ.ត.ក. បានសម្រេចជ្រើសរើសយក យុត្តាធិការបែបជ្រើសរើស ដែលក្នុងនោះ មានបុគ្គលពីរប្រភេទ មេ)ដឹកនាំជាន់ខ្ពស់ និងជនដែលទទួលខុសត្រូវខ្ពស់បំផុត (តែប៉ុណ្ណោះ ស្ថិតក្នុងសមត្ថកិច្ចរបស់ អ.វ.ត.ក.។ ក្នុងការសម្រេចថាបុគ្គលណាមួយចូលក្នុងយុត្តាធិការបុគ្គល សហចៅក្រមស៊ើបអង្កេតជាតិ បានពិចារណា លើតួនាទី និងកម្រិតនៃការចូលរួមរបស់ជនសង្ស័យ។ សហចៅក្រមស៊ើបអង្កេតជាតិ ផ្តោតជាសំខាន់ទៅលើការចូលរួម ហើយក្នុងពិចារណា ការប្រៀបធៀបការចូលរួម របស់ជនសង្ស័យ និងជនសង្ស័យដទៃទៀត ក៏ត្រូវបានពិចារណាផងដែរ។

មានទីតាំង បទឧក្រិដ្ឋចំនួន ៥០ ។ ភាគច្រើននៃទីតាំងទាំងនេះ ត្រូវបានបង្កើតតាំងពីឆ្នាំ ១៩៧៥ ឬ ១៩៧៦ បន្តរហូតដល់ចុងឆ្នាំ ១៩៧៨ មុនពេលដែលកម្មាភិបាលនិរតីបានទៅដល់ភូមិភាគពាយ័ព្យ។ មានទីតាំងចំនួនតិចដែល ត្រូវបានដាក់ដំណើរការ ក្រោយពេលកម្មាភិបាលនិរតីបានទៅដល់ភូមិភាគពាយ័ព្យ មន្ទីរសន្តិ)សុខទ្រយោង។ មានទីតាំង(មួយស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការមជ្ឈិម សន្តិសុខវត្តមន្ទីរ)កណ្តាល។ ទីតាំងខ្លះ ត្រូវបានបង្កើតមុន( ពេលដែល**យឹម ទិត្យ** បានទទួលតួនាទីជា លេខាស្រុកគីរីវង់ និងដោយឡែក ទីតាំងខ្លះនៅក្នុងតំបន់ ១ ត្រូវបានបិទដំណើរការក្នុងពាក់កណ្តាលឆ្នាំ ១៩៧៨ នាពេល **យឹម ទិត្យ** ត្រូវបានតែងតាំងជាលេខាតំបន់ ១ ជំនួស តាហេង ទាវហៅប៉ែត។

មានទីតាំងចំនួន ២៤ ត្រូវបានដាក់ក្រោមការស៊ើបសួរ ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងនោះស្ថិតក្នុងស្រុកគីរីវង់ មានចំនួន ៤ និង ៧ ទីតាំងស្ថិតក្នុងភូមិសាស្ត្រនៃតំបន់ ១។ ទីតាំង ចំនួន ២៦ ត្រូវបានលើកចោលដោយសារមិនមានព័ត៌មានច្រើនពាក់ព័ន្ធនឹង **យឹម ទិត្យ**ទីតាំង ស្ថិតក្រោមស្រុកគីរីវង ២) ់ និង ៦ ក្រោមតំបន់១ ។( អាស្រ័យហេតុនេះ ទីតាំងចំនួន ៣៩ ដាក់ក្រោមស៊ើប)សួរ និងមិនដាក់ក្រោមការស៊ើបសួរពីការឃោលស្ថិតនៅប្រ ( គ្រប់គ្រង ហើយត្រូវបានចោទប្រកាន់ ដោយសារ **យឹម ទិត្យ** ជាលេខាតំបន់ ១៣ (ភូមិភាគនិរតី( ឬ ជាសមាជិកគណៈភូមិភាគពាយ័ព្យ។ មានតែអង្គហេតុមួយចំនួនដែលបង្ហាញថា **យឹម ទិត្យ** បានពាក់ព័ន្ធ ដូចជា មន្ទីរសន្តិសុខវត្តប្រធាតុ ការដ្ឋានទំនប់កង្កួត ការដ្ឋានរោងចក្រស្ករសកំពង់គុល និង ការរៀបការដោយបង្ខំនៅស្រុកសំឡូត។

សហព្រះរាជអាជ្ញាអន្តរជាតិ អះអាងថា **យឹម ទិត្យ** ធ្លាប់ជាលេខាស្រុកគីរីវង់ លេខាតំបន់ ១៣ នៃ ភូមិភាគនិរតី។ ស្រុកគីរីវង់ ស្ថិតនៅក្នុងភូមិសាស្ត្រនៃតំបន់ ១៣។ គាត់ជាលេខាតំបន់ ១ នៃភូមិភាគពាយ័ព្យ ហើយដែលត្រូវបាន គេអះអាងថា គាត់ជា សមាជិកនៃគណៈភូមិភាគនេះផងដែរ។ ភូមិភាគនិរតី ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ តាម៉ុក ហើយ ភូមិភាគពាយ័ព្យ គ្រប់គ្រងដោយរស់ ញឹម រហូតដល់ពាក់កណ្តាលឆ្នាំ ១៩៧៨ ជំនួយដោយ តាម៉ុក មកពីភូមិភាគនិរតី នៅពេលដែលគាត់ជាលេខាភូមិភាគនិរតីផងដែរ។

ភ័ស្តុតាង បានបង្ហាញពីតួនាទីទាំងនេះ តាមរយៈការលើត១គ្នា ដោយគ្មានឯកសារជាផ្លូវការនៃរបបកម្ពុជាប្រជាធិបតេយ្យបញ្ជាក់ទេ។ បន្ថែមពីលើនេះ កាលបរិច្ឆេទដែល **យឹម ទិត្យ** បានកាន់ដំណែងទាំងនេះ ក៏មិនមាន ភាពច្បាស់លាស់ផងដែរ។ ភ័ស្តុតាង ទំនងជាបង្ហាញថា យឹម ទិត្យ ទទួលបានដំណែងទាំងនេះ នៅក្នុងចុងរបបកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ ១៩៧៨ ក្នុងភូមិភាគពាយ័ព្យ ឬ ក្នុងរយៈពេលខ្លី នៅភូមិភាគនិរតី មុនពេលគាត់ត្រូវបានបញ្ជូនទៅ ភូមិភាគពាយ័ព្យនៅពាក់កណ្តាលឆ្នាំ ១៩៧៧ ដើម្បីបង្ក្រាបកម្មាភិបាលពាយ័ព្យ តាមគោលនយោបាយបង្ក្រាប។ ការស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតជាតិ មិនបានបង្ហាញថា **យឹម ទិត្យ** ជាសមាជិកគណៈកម្មាធិការមជ្ឈិម ឬជាតំណាងរាស្ត្រទេ។ គាត់ក៏គ្មានតួនាទីអ្វីក្នុងកងទ័ពផងដែរ។

សជ.ស.ច. បានពិនិត្យឯកសារច្បាប់ដើម របស់របបកម្ពុជាប្រជាធិបតេយ្យដែលមាននៅសេសសល់ដូចជា កំណត់ត្រាអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ នៃគណៈកម្មាធិការមជ្ឈិមបក្ស តេឡេក្រាមឆ្លងឆ្លើយរវាងកម្មាភិបាលតំបន់ ភូមិភាគ និង គណៈកម្មាធិការអចិន្ត្រៃយ៍ តែមិនបានរំលេចឃើញឈ្មោះ **យឹម ទិត្យ** ឬ តួនាទីរបស់គាត់ក្នុងឯកសារទាំងនេះឡើយ។ប្រសិនបើប្រៀបធៀបនឹង ជនសង្ស័យ **អោ អាន** និង (កណ្តាលនៃភូមិភាគ ៤១លេខាតំបន់) **មាស មុត** ១៦៤ បញ្ជាការកងពលមជ្ឈិមលេខមេ)) ដែលត្រូវបានលើកលែងចោទ មានភ័ស្តុតាងជាប្រភេទតេឡេក្រាម និង កំណត់ត្រាកិច្ចប្រជុំ បានរំលេចឈ្មោះ **អោ អាន** ក្នុងតេ)ឡេក្រាម ដែលលេខាភូមិភាគកណ្តាល កែ ពក ជូនទៅគណៈកម្មាធិការមជ្ឈិមបក្ស ( និង **មាស មុត**។

**យឹម ទិត្យ** ស្ថិតនៅក្នុងលំដាប់ទី ៤ រាប់ពីគណៈកម្មាធិការអចិន្ត្រៃយ៍គណៈកម្មាធិការមជ្ឈិមបក្សរហូតដល់ថ្នាក់តំបន់ និងជាមនុស្សម្នាក់ក្នុងចំណោមមនុស្ស យ៉ាងតិច ១០០ រូបក្នុងកម្រិតតំបន់។ គាត់មិនមែនស្ថិតក្នុងចំណោមបុគ្គល ១៣ រូប ដែលមានសិទ្ធិកំទេចរួមមាន លេខាភូមិភាគ ដូចជា តាម៉ុក តាមសេចក្តីសម្រេច ថ្ងៃទី៣០ ខែ មីនា ឆ្នាំ១៩៧៦ ឡើយ ។ទាំងនៅក្នុង ភូមិភាគនិរតី និងពាយ័ព្យ គាត់ស្ថិតនៅក្រោម លេខាភូមិភាគ ដ៏មានឥទ្ធិពល តា ម៉ុក និង រស់ ញឹម ដែល រស់ ញឹម ត្រូវបានចាប់ខ្លួន ៦ ខែមុនដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងចុងឆ្នាំ១៩៧៨។

**យឹម ទិត្យ** អាចមានឋានៈស្រដៀងនឹង **អោ អាន** និងខ្ពស់ជាង **ឌុច** មែន ក៏ប៉ុន្តែ ជាសត្យានុម័ត កម្មាភិបាលកាន់តំណែងធំខ្លះមិនប្រាកដថា មានអំណាចច្រើននោះទេ។ **យឹម ទិត្យ** មានតួនាទីក្នុងភូមិ ភាគពាយ័ព្យ ក៏ប៉ុន្តែ មិនមានអ្នកក្រោមបង្គាប់ជាក់លាក់ច្បាស់លាស់ ដែលនេះផ្ទុយពី **ឌុច** គ្រប់គ្រងមន្ទីរសន្តិសុខមជ្ឈិម ២១ស)) មានវចនាសម្ព័ន្ធដឹកនាំក្រោមបង្គាប់យ៉ាងជាក់លាក់ ដែលធ្វើឲ្យ **ឌុច** ចូលរួមក្នុងបទឧក្រិដ្ឋយ៉ាងសកម្ម បង្កឲ្យមនុស្សជាង ១២ ០០០, មួយម៉ឺនពីរពាន់នាក់ស្លាប់ ដោយអំពើផ្ទាល់ និង (ប្រយោលរបស់គាត់ តាមរយៈដឹកនាំ ចាត់ចែង និង គ្រប់គ្រង មន្ទីរសន្តិសុខប្រកបដោយប្រសិទ្ធភាពក្នុងអំឡុងពេលស្ទើរពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ ។

ជាសរុប ការចូលរួមរបស់ យឹម ទិត្យ ជារួម ជាពិសេស ក្នុងទីតាំងបទល្មើសទាំង៤ ខាងលើនេះ វាត្រឹមតែជាការចូលរួមដឹងឮជាការចូលរួមមិនសកម្ម គ្មានគំនិតផ្តួចផ្តើម ឬចូលរួមក្នុងកម្រិតនៃកម្មាភិបាលម្នាក់ ក្នុងចំណោមកម្មាភិបាលកម្រិតស្រុក តំបន់ ឬភូមិភាគជាច្រើនរូបទៀត។ វាជាការចូលរួមអនុវត្តការងារតាមគោលនយោបាយបក្សដែលត្រូវតែគោរពនិងធ្វើតាម បើមិនដូច្នោះទេ នឹងត្រូវគេយកទៅសម្លាប់ចោល។

ការចូលរួមក្នុងកម្រិតខាងលើ មិនស្ថិតក្នុងលក្ខណវិនិច្ឆ័យនៃជនទទួលខុសត្រូវខ្ពស់បំផុត ដែលផ្តោតជាចម្បងលើសកម្មភាពចូលរួមជាក់ស្តែង និងដោយផ្ទាល់ មិនសំដៅលើឋានៈជាចម្បង ។ យើងយល់ឃើញថា មិនមានភស្តុតាងដែលអាចអោយយើងរកឃើញថា **យឹម ទិត្យ**គឺជា មេដឹកនាំជាន់ខ្ពស់ ឬ ក៏ជាជនទទួលខុសត្រូវខ្ពស់បំផុតនៅក្នុងរបបខ្មែរក្រហមទេ។ អាស្រ័យហេតុនេះ អ មានយុត្តាធិការបុគ្គលលើគាត់ឡើយ។មិន .ក.ត.វ.

# សេចក្តីសង្ខេបរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានរកឃើញថា អ.វ.ត.ក មានយុត្តាធិការបុគ្គលលើ យឹម ទិត្យ ជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់គឺជាមន្ត្រីខ្មែរក្រហមនៅក្នុងអំឡុងពេលនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក និងនៅក្នុងអំឡុងពេលដែលបទល្មើសត្រូវបានចោទថាបានកើតឡើងដោយសារគាត់។

ពាក់ព័ន្ធនឹងឋានៈផ្លូវការរបស់គាត់ គាត់បានឡើងតួនាទីយ៉ាងឆាប់រហ័សណាស់ពីអនុលេខាស្រុកនៅភូមិភាគនិរតី ទៅអនុលេខាភូមិភាគ ហើយនៅជិតចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ប្រហែលអាចក្លាយជាលេខាភូមិភាគពេញសិទ្ធិផងនៅភូមិភាគពាយ័ព្យ។ ជាងនេះទៀត គាត់គឺជាលេខាតំបន់សម្រាប់តំបន់មួយចំនួននៅភូមិភាគពាយ័ព្យផងដែរ។ ហេតុនេះ អំណាចរបស់គាត់នៅក្រោមច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា មានវិសាលភាពវែងឆ្ងាយណាស់ទាំងភូមិសាស្ត្រ ទាំងឋានានុក្រម។

តំណែងផ្លូវការរបស់គាត់ និងការឡើងតំណែងយ៉ាងឆាប់រហ័សរបស់គាត់ មានការជួយជ្រោមជ្រែងពីទំនាក់ទំនងគ្រួសារយ៉ាងជិតស្និទ្ធរបស់គាត់ជាមួយនឹងកម្មាភិបាលម្នាក់នៅឋានានុក្រមថ្នាក់លើរបស់បក្សកុម្មុយនីស្តកម្ពុជា គឺ តា ម៉ុក ដែលជាបងថ្លៃរបស់គាត់។ សូម្បីតែពេលមុនគាត់កាន់តំណែងផ្លូវការនៅភូមិភាគពាយ័ព្យក៏ដោយ ក៏គេអាចឃើញគាត់ធ្វើដំណើរនៅទូទាំងភូមិភាគពាយ័ព្យ ជាមួយ តា ម៉ុក ដោយចូលរួមអង្គប្រជុំនានា ជាដើម ។ល។ ជាក់ស្តែង គាត់គឺជាមេបញ្ជាការបន្ទាប់ពី តា ម៉ុក ហើយដូចដែលភស្តុតាងបានបង្ហាញដែរ គាត់ក៏នៅមានអំណាចជាក់ស្តែងលើតំបន់ប្រតិបត្តិការពីមុនរបស់គាត់នៅភូមិភាគនិរតី ផងដែរ សូម្បីតែក្រោយពេលដែលគាត់បានផ្លាស់ទៅភូមិភាគពាយ័ព្យក៏ដោយ។

ភាពធ្ងន់ធ្ងរនៃអំពើរបស់គាត់ ក៏ជួយបញ្ជាក់អំពីការរកឃើញដែលថា គាត់គឺជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅសម័យកម្ពុជាប្រជាធិបតេយ្យ។ សូម្បីតែក្រោយពេលដែលបានកាត់បន្ថយទីតាំងឧក្រិដ្ឋកម្មចំនួនជិតពាក់កណ្តាលយោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន ចេញពីបញ្ជីឈ្មោះទីតាំងឧក្រិដ្ឋកម្មដើមតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរយ៉ាងណាក៏ដោយ ក៏គាត់នៅតែត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មចំនួនជាង ២០ កន្លែងទាំងនៅភូមិភាគនិរតី ទាំងនៅភូមិភាគពាយ័ព្យ ឧទាហរណ៍ នៅភូមិភាគនិរតី មាននៅតំបន់ ១៣ (មន្ទីរសន្តិសុខវត្តប្រធាតុ មន្ទីរសន្តិសុខក្រាំងតាចាន់ ទីតាំងសម្លាប់មនុស្សភូមិព្រៃល ទីតាំងសម្លាប់មនុស្សវត្តអង្គុណា ទីតាំងសម្លាប់មនុស្សព្រៃភូមិស្តែង ទីតាំងសម្លាប់ព្រៃសុខុន និងវត្តអង្គសិរីមុនី) និងនៅភូមិភាគពាយ័ព្យ មានតំបន់ ១ (មន្ទីរសន្តិសុខគាស់ក្រឡ សហករណ៍ធិបតី (រួមមាន មន្ទីរសន្តិសុខវត្តធិបតី និង មន្ទីរសន្តិសុខ និងការដ្ឋានទួលម្ទេស) ការដ្ឋានទំនប់កង្ហត មន្ទីរសន្តិសុខខ្នងគូ ការដ្ឋានរោងចក្រស្ករកំពង់គុល មន្ទីរសន្តិសុខបាណន់ និងស្រុកសំឡូត) តំបន់ ២( មន្ទីរសន្តិសុខភ្នំវាល មន្ទីរសន្តិសុខស្វាយជ្រំ ទីតាំងសម្លាប់មនុស្សទួលសេះញ៉ូវ

ទីតាំងសម្លាប់មនុស្សព្រៃក្របៅ) តំបន់ ៣(មន្ទីរសន្តិសុខវត្តគិរីរម្យ) តំបន់ ៤(មន្ទីរសន្តិសុខវត្តសម្តេច ឃុំកំពង់ព្រៀង (រួមមាន មន្ទីរសន្តិសុខវត្តពោធិ៍លង្ការ/កាច់រទេះ កាច់រទេះ ភូមិថ្មី និងភូមិសាលាត្រាវ) និងឃុំវាំងកេសី) និងតំបន់ ៧(គុកលេខ ៨ និងទីតាំងសម្លាប់មនុស្សវាលបាក់ជញ្ជីង)។

ឧក្រិដ្ឋកម្មដែល យឹម ទិត្យ ទទួលខុសត្រូវ មានចាប់ពីអំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាល រហូតដល់ឧក្រិដ្ឋកម្មជាច្រើនផ្សេងទៀតក្នុងចំណោមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងការធ្វើមនុស្សឃាតដែលស្ថិតនៅក្រោមច្បាប់ជាតិ។

ត្រង់នេះ ចំណុចដែលលេចធ្លោគឺថា គាត់បានចូលរួម និងរៀបចំអំពើប្រល័យពូជសាសន៍ខ្មែរក្រោមនៅតំបន់ទទួលខុសត្រូវរបស់គាត់។ ដូចជនត្រូវចោទនៅក្នុងសំណុំរឿង ០០៤/២ និងសំណុំរឿង ០០៣ ដែរ អង្គហេតុនេះតែមួយធ្វើឱ្យគាត់ស្ថិតនៅក្នុងរង្វង់នៃយុត្តាធិការបុគ្គលយ៉ាងច្បាស់រួចទៅហើយ។ វិសាលភាពនៃការដាក់គោលដៅប្រល័យពូជសាសន៍ខ្មែរក្រោម ដោយផ្អែកលើជាតិពិន្ទុជាខ្មែរក្រោម ត្រូវបានបញ្ជាក់តាមរយៈអង្គហេតុដែលថា ក្នុងករណីខ្លះ ខ្មែរក្រោម ត្រូវបានផ្លាស់ទីពីកម្ពុជាក្រោមនៅវៀតណាម មកកម្ពុជាប្រជាធិបតេយ្យ បន្ទាប់មក ត្រូវបានសម្លាប់នៅកម្ពុជាប្រជា ធិបតេយ្យ។ ភ័ស្តុតាងនៅក្នុងសំណុំរឿងនេះអំពីចំនួនខ្មែរក្រោមដែលត្រូវបានសម្លាប់ បានទទួលរងការខូចខាតជាពិសេសដោយសារថា ភ័ស្តុតាងសាក្សីតាមធម្មតាត្រូវបាត់បង់ ប៉ុន្តែ យ៉ាងណាក៏ដោយ នៅតែមានរូបភាពអំពីយុទ្ធនាការឃោរឃៅយុងឃ្នងនៃការបោសសម្អាតជាតិពន្ធុ ហើយយុទ្ធនាការនេះត្រូវបានបញ្ឈប់នៅពេលដែលវៀតណាមចូលមកដល់ និងចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះ ចំណែកឯ ចំនួនមនុស្សស្លាប់ទោះបីជាប៉ាន់ស្មានយ៉ាងអភិរក្សនិយមយ៉ាងណាក៏ដោយ ក៏ចូលខ្ទង់រាប់ពាន់នាក់ដែរ ហើយចំនួននេះនឹងកើនឡើងថែមទៀតប្រសិនបើយុទ្ធនាការនោះមិនបានឈប់ទេ។

ក្រៅពីដាក់គោលដៅប្រល័យពូជសាសន៍ខ្មែរក្រោម ជនស៊ីវិលផ្សេងទៀត និងអតីតកម្មាភិបាលនៃបក្សកុម្មុយនីស្តកម្ពុជា បានក្លាយជាជនរងគ្រោះចំនួនរាប់ម៉ឺននាក់នៅក្រោមការគ្រប់គ្រងរបស់ យឹម ទិត្យ និងដោយសារគាត់ តាមចក្ខុវិស័យនយោបាយបំភាន់ និងដឹកនាំខុសរបស់បក្សកុម្មុយនីស្តកម្ពុជា តាមរយៈការសម្លាប់រួមជាបន្តបន្ទាប់ និងមានការរៀបចំបានយ៉ាងល្អ ព្រមទាំងការប្រព្រឹត្តិយ៉ាងឃោរឃៅ និងអមនុស្សធម៌ តាមរយៈការដាក់ក្នុងមន្ទីរឃុំឃាំង និងពលកម្មយ៉ាងធ្ងន់ធ្ងរក្នុងស្ថានភាពមិនអាចពិពណ៌នាបាន នៅក្នុងមន្ទីរសន្តិសុខ និងតាមការដ្ឋាន។ កម្រិតនៃការប្រមាថលើសេចក្តីថ្លៃថ្នូរមនុស្សជាតិដែលបានបង្ហាញនៅមន្ទីរសន្តិសុខ និងការដ្ឋាន ព្រមទាំងកម្រិតនៃភាពអមនុស្សធម៌របស់អ្នកដែលដំណើរការមន្ទីរសន្តិសុខ និងការដ្ឋានទាំងនោះ អាចប្រៀបធៀបដូចគ្នានឹងអំពើឃោរឃៅនៅជំរុំកែប្រែនៅរបបណាហ្ស៊ីអាល្លឺម៉ង់។

មានការអនុវត្តកម្រិតដូចគ្នាចំពោះករណីការប្រមាថលើជម្រើសជីវិតរបស់មនុស្សម្នាក់ៗ ជាពិសេសការសម្រេចចិត្តរបស់មនុស្សម្នាក់ៗលើបញ្ហាផ្លូវភេទ តាមរយៈគោលនយោបាយរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ យឹម ទិត្យ និងអ្នក

ដែលគាត់បានសហការជាមួយ បានធ្វើឱ្យមនុស្សប្រុស និងមនុស្សស្រី ឆ្លងកាត់ការពិសោធន៍សង្គមគួរឱ្យស្អប់ខ្ពើមរបស់បក្សកុម្មុយនីស្តកម្ពុជាដែលកាត់បន្ថយទំនៀមទម្លាប់រៀបអាពាហ៍ពិពាហ៍មកនៅត្រឹមតែពិធីបង្កាត់ពូជមនុស្សទៅវិញ និងដើម្បីបង្កើនចំនួនប្រជាជនខ្មែរដោយគ្មានមនោសញ្ចេតនាជាមនុស្ស ប៉ុន្តែពោរពេញដោយភាពភ័យខ្លាច ខ្ពើមរអើម កំហឹង និងការអន់ចិត្តរហូត។ ការអនុវត្តគោលនយោបាយនេះធ្វើឱ្យប៉ះពាល់ដល់ជីវិតរបស់ប្រជាជនខ្មែរជាច្រើននាក់ អស់ជាច្រើនទសវត្ស។ ទាំងបុរស ទាំងនារី សុទ្ធតែទទួលរងការឈឺចាប់ ប៉ុន្តែ ផលប៉ះពាល់សំខាន់ធ្លាក់ទៅលើជនរងគ្រោះជានារី ដែលជារឿយៗត្រូវបានចាត់ទុកថាគ្រាន់តែជាមនុស្សគេប្រើប្រាស់សម្រាប់ឱ្យទៅយោធាដែលពិការនៅក្នុងសមរភូមិ ហេតុនេះ ជនរងគ្រោះជានារីមានការលំបាកក្នុងការស្វែងរកដៃគូតាមរយៈទំនាក់ទំនងការចែចូវគ្នាជា ធម្មតា។ តាមពិត នារីទាំងនេះត្រូវបានចាត់ទុកដូចជាឧបករណ៍/ទំនិញ តាមទម្លាប់អាកប្បកិរិយាហួសសម័យដែលតាមរយៈមនោគមវិទ្យាមើលទៅស្មើភាពគ្នា និងកុម្មុយនីស្តរបស់បក្សកុម្មុយនីស្តកម្ពុជា នៅតែអះអាងដោយប្រយោលថា បុរស ឬសង្គម មានសិទ្ធិម្យ៉ាងរួចជាស្រេចតាំងពីកំណើត ឬការគ្រប់គ្រងលើខ្លួនប្រាណ និងផ្លូវភេទរបស់នារី។ ទម្លាប់អាកប្បកិរិយាគ្រប់គ្រងសិទ្ធិបែបនេះនៅក្នុងករណីជាច្រើន បានបង្ហាញយ៉ាងច្បាស់តាមរយៈការតាមដាន "ការផ្សំដំណេកក្រោយរៀបការ" នៅក្នុងបរិបទនេះពាក្យថា ផ្សំដំណេក គ្រាន់តែជាពាក្យគួរសមដែលមានន័យថាជាការរំលោភសេពសន្ថវៈ។

យឹម ទិត្យ បានដើរតួនាទីយ៉ាងសំខាន់ណាស់នៅក្នុងអំពើឃោរឃៅទាំងអស់ដែលបានរៀបរាប់ខាងលើ ហើយបានដើរតាមទាំងស្រុងតាមស្ទួលមនោគមវិទ្យានៃគំរូសង្គមអមនុស្សធម៌របស់បក្សកុម្មុយនីស្តកម្ពុជា និងអនុវត្តតាមគំរូនេះ។ តួនាទី និងសកម្មភាពរបស់គាត់ ងាយធ្វើការប្រៀបធៀបដូចគ្នាជាមួយនឹងតួនាទី និងសកម្មភាពរបស់ អោ អាន ឬ មាស មុត ជាឧទាហរណ៍ ហើយច្បាស់ណាស់ គឺដូចគ្នាជាមួយនឹងតួនាទី និងសកម្មភាពរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច"។ តួនាទី និងសកម្មភាពរបស់ យឹម ទិត្យ ថែមទាំងលើសខ្លាំងជាងនោះមួយចំនួនផង។ ហេតុនេះ ច្បាស់ណាស់ គឺថា យឹម ទិត្យ ស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក។ គាត់គួរត្រូវជំនុំជម្រះក្តីចំពោះឧក្រិដ្ឋកម្មរបស់គាត់។